# សិក្ខាសាលាប្រចាំឆ្នាំស្តីពី
# ការអនុវត្តធ្វើតេស្តបន្ទុកមេរោគអេដស៍លើស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅកូនដោយទឹកដោះ និង កុមារប្រឈមនឹងការឆ្លងមេរោគអេដស៍ ដោយប្រើម៉ាស៊ីន GeneXpert (POC-PMTCT)

- ដើម្បីពិនិត្យមើលការអនុវត្ត ការធ្វើតេស្តបន្ទុកមេរោគអេដស៍ នៅកន្លែងថែទាំ សម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូនដោយទឹកដោះ និងកុមារប្រឈមនឹងការឆ្លងមេរោគអេដស៍ដោយប្រើប្រាស់ម៉ាស៊ីន GeneXpert ទាំង១៥ មន្ទីរពេទ្យ
- ដើម្បីកំណត់បញ្ហាប្រឈមជាក់ស្តែង និងដំណោះស្រាយសម្រាប់ការកែលម្អ
- ដើម្បីកសាងសមត្ថភាពរបស់អ្នកផ្តល់សេវាអំពីរបៀបគ្រប់គ្រង ការធ្វើតេស្ត ការកត់ត្រា បញ្ចូលទិន្នន័យ របាយការណ៍ VL-EID ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

**The Annual workshop on review Point-of-care for HIV viral load for pregnant and breastfeeding women and exposed infants using GeneXpert**

- To review the implementation of HIV testing in Point-of-care for HIV viral load for pregnant and breastfeeding women and exposed infants using GeneXpert in 15 sites.
- To identify the real challenges and determined the solutions for improvement.
- To build the capacity of service providers on how to manage testing, recording, data entry, VL-EID reporting accurately and in a timely manner.





*ថ្ងៃ ពុធ ១ រោច ដល់ ថ្ងៃ ព្រហស្បតិ៍ ២ រោច ខែ ទុតិយសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧*

*ត្រូវនឹងថ្ងៃទី ២-៣ ខែ សីហា ឆ្នាំ ២០២៣*

*នៅខេត្ត កំពង់ចាម ”*

**អ្នកចូលរួមមាន:**

- ក្រុមការងារនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- ក្រុមការងារនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
- ក្រុមការងារនៃមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន
- អង្គការ CHAI
- សិក្ខាកាមមកពីខេត្តចំនួន ១២ គឺ គឺ ខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន សៀមរាប កំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង រតនគិរី តាកែវ កំពង់ស្ពឺ កំពត និងព្រះសីហនុ ចូលរួមដូចជា PASP, គ្រូពេទ្យ ART ទទួលបន្ទុកកុមារ, ផ្នែកសម្ភពទទួលបន្ទុក PMTCT, និងបុគ្គលិកមន្ទីរពិសោធន៍ GeneXpert។ រួមសិក្ខាកាមទាំងអស់ចំនួន ៦៤ នាក់។

## ពិធីបើក

នាព្រឹកថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២៣ សិក្ខាសាលានេះបានចាប់ផ្តើមនៅម៉ោង 8:00 ព្រឹក

- លោកវេជ្ជ. **ង៉ូវ ប៊ូរ៉ា** តំណាងឱ្យមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានមានមិតិស្វាគមន៍និងចំណាប់អារម្មណ៍ ដល់អង្គសិក្ខាកាម និងជម្រាបជូនពីគោលបំណងនៃសិក្ខាសាលានេះ។
- លោកវេជ្ជ. **ណារិទ្ធ រដ្ឋា** តំណាងមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន បានមានមិតិ និងចំណាប់អារម្មណ៍ នៃសិក្ខាសាលានេះ។
- លោកវេជ្ជ. **ឈុន សំណាង** តំណាងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក បានមានមិតិ និងចំណាប់អារម្មណ៍ នៃសិក្ខាសាលានេះ។